អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គនាយកដ្ឋានស្រាវជ្រាវ

នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

## មាតិកា៖

- ➢ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការសង្គ្រោះជាលើកទី៨
- ➢ ថវិកា ២០០លានដុល្លារ នៃគម្រោងធានាអាជីវកម្មត្រូវបានបង្កើតឡើងដោយសាជីវកម្មធានាឥណទានកម្ពុជា ដើម្បីជួយគាំទ្រដល់អាជីវកម្ម
- ➢ ការប្រៀបធៀបតម្លៃផលិតផលនាំចេញប្រចាំខែកុម្ភៈ ឆ្នាំ២០២១ កំណើន ២៤% ធៀបនឹងខែមុន
- ➢ អត្រានៃការលក់រាយរបស់ប្រទេសជប៉ុនបានធ្លាក់ចុះក្នុងរយៈពេលបីខែជាប់គ្នា គិតត្រឹមខែកុម្ភៈ
- ➢ តម្រូវការទីផ្សារការងារ ដែលមានភាពពេញនិយមនៅប្រទេសថៃកាលពីខែមុន
- ➢ តម្លៃប្រេងកើនឡើង ដោយសារតែពាណិជ្ជកររំពឹងថា អង្គការ OPEC+ នឹងរក្សាការកាត់បន្ថយការផលិតប្រេង
- ➢ ជាងមួយភាគប្រាំនៃក្រុមហ៊ុននាំចេញតូចៗ របស់ចក្រភពអង់គ្លេស បញ្ឈប់ការលក់ជាបណ្តោះអាសន្នទៅកាន់សហភាពអឺរ៉ុប

ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

ចងក្រង និងបូកសរុបដោយ

- ជីម ប៊ុនធឿន ប្រធានការិយាល័យវិភាគចំណូល-ចំណាយ

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការសង្គ្រោះជាលើកទី៨



*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ២០២១, រូបភាព៖ ហេង ជីវន្ត*

រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសពីវិធានការលើកទី៨ របស់ខ្លួន ដើម្បីរក្សាអាជីវកម្មឱ្យរីកលូតលាស់ និងជំរុញកំណើនសេដ្ឋកិច្ច កាលពីថ្ងៃទី២៥ ខែមីនា ខណៈពេលដែលព្រះរាជាណាចក្រកម្ពុជាកំពុងប្រយុទ្ធប្រឆាំងនឹងការឆ្លងជំងឺកូវីដ-១៩។

វិធានការជំនួយផ្តោតសំខាន់លើវិស័យសម្លៀកបំពាក់ វាយនភណ្ឌ ស្បែកជើង ទំនិញទេសចរណ៍ កាបូប និងវិស័យទេសចរណ៍ ហើយក្នុងខែមេសា ដល់ មិថុនា រាជរដ្ឋាភិបាលនឹងបន្តផ្តល់ប្រាក់៤០ដុល្លារក្នុងមួយខែដល់កម្មករ ដែលជាផ្នែកមួយនៃកម្មវិធីបញ្ចេញសាច់ប្រាក់របស់ខ្លួនកំឡុងពេលមានជំងឺរាតត្បាត ខណៈដែលម្ចាស់រោងចក្រ និងសហគ្រាស ត្រូវបន្ថែមប្រាក់ចំនួន ៣០ដុល្លារ ដែលសរុបស្មើចំនួន ៧០ដុល្លារ នៅក្នុងវិស័យកាត់ដេរ។ ម៉្យាងវិញទៀត និយោជកក្នុងវិស័យទេសចរណ៍ត្រូវបានលើកទឹកចិត្តឲ្យឧបត្ថម្ភសាច់ប្រាក់ដោយការស្ម័គ្រចិត្តតាមដែលអាចធ្វើទៅបាន។

វិស័យឯកជនដែលបានចុះបញ្ជី ដូចជា សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងភ្នាក់ងារទេសចរណ៍ នឹងត្រូវរួចផុតពីពន្ធ សម្រាប់រយៈពេល ៣ខែបន្ទាប់ ប៉ុន្តែនៅតែតម្រូវឱ្យបង់ពន្ធកាត់ទុក និងប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណេត e-VAT សម្រាប់គ្រប់គ្រងពន្ធលើតម្លៃបន្ថែម(VAT) របស់ពួកគេជារៀងរាល់ខែ។ ទោះជាយ៉ាងណា ការលើកលែងនេះ អនុវត្តចំពោះអាជីវកម្មទេសចរណ៍នៅក្នុងខេត្តកំពត ព្រះសីហនុ កែប សៀមរាប រាជធានីភ្នំពេញ ក្រុងបាវិតខេត្តស្វាយរៀង និងក្រុងប៉ោយប៉ែតខេត្តបន្ទាយមានជ័យ ប៉ុណ្ណោះ។

តាមរយៈក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជរដ្ឋាភិបាលនឹងពង្រីកកម្មវិធីចែកថវិកាដល់ប្រជាជនក្រីក្រ និងងាយរងគ្រោះ ដែលរងផលប៉ះពាល់ដោយជំងឺកូវីដ-១៩ នៅក្នុងជុំទី៥ ចាប់ពីខែមេសា ដល់ខែមិថុនា។ រាជរដ្ឋាភិបាល ក៏បានអំពាវនាវដល់ក្រសួង ស្ថាប័នសាធារណៈ និងម្ចាស់កម្មសិទ្ធិឯកជននៃពាណិជ្ជកម្មជួលអចលនវត្ថុ ដើម្បីចៀសវាងពីការបញ្ចប់កិច្ចសន្យាជាមួយ

ឬបណ្ដេញអ្នកជួល ដែលមិនមានលទ្ធភាពបង់ថ្លៃជួល ឱ្យបានទាន់ពេលវេលា។

រាជរដ្ឋាភិបាលនឹងបន្តឃ្លាំមើលជាប្រចាំនូវស្ថានភាព ជំងឺកូវីដ-១៩ ស្ថានភាពសេដ្ឋកិច្ច សង្គម និងហិរញ្ញវត្ថុ នៅលើពិភពលោក ក្នុងតំបន់ និងក៏ដូចជាក្នុងប្រទេស ដើម្បីពិនិត្យ និងវាយតម្លៃផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើវិស័យសំខាន់ៗនៃសេដ្ឋកិច្ចរបស់កម្ពុជា ដើម្បីធ្វើបច្ចុប្បន្នភាព និងត្រៀមខ្លួនចេញវិធានការចាំបាច់បន្ថែមទៀត ក្នុងគោលបំណងស្តារ និងជំរុញកំណើនសេដ្ឋកិច្ចក្រោមក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រស្តារសេដ្ឋកិច្ចឡើងវិញក្នុងកំឡុងពេល និងក្រោយពេលមានវិបត្តិជំងឺកូវីដ-១៩៕ *ដោយ វត្តា វង្សវឌ្ឍនៈ*

*ប្រភព៖ Phnom Penh Post ចេញផ្សាយថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១*

## ថវិកា ២០០ លានដុល្លារ នៃគម្រោងធានាអាជីវកម្ម ត្រូវបានបង្កើតឡើងដោយសាជីវកម្មធានាឥណទានកម្ពុជា ដើម្បីជួយគាំទ្រដល់អាជីវកម្ម



*ប្រភព៖ Khmer Times ២០២១*

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដាក់ឱ្យដំណើរការនូវគម្រោងធានាអាជីវកម្ម (BRGS) ដោយសាជីវកម្មធានាឥណទានកម្ពុជា (CGCC)។ BRGS មានគោលបំណងជួយដល់អាជីវកម្ម រួមមាន សហគ្រាសមីក្រូ តូច និងមធ្យម និងក្រុមហ៊ុនធំៗ ដើម្បីបង្កើនលទ្ធភាពទទួលបានប្រាក់កម្ចីក្នុងប្រព័ន្ធពីស្ថាប័នហិរញ្ញវត្ថុដែលចូលរួម(PFIs) សម្រាប់ជាដើមទុនលើការវិនិយោគ និងការពង្រីកអាជីវកម្ម។ គំនិតផ្តួចផ្តើមនេះ គឺស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការគាំទ្រដល់ការរស់រានមានជីវិត និងការងើបឡើងវិញនៃសេដ្ឋកិច្ចក្នុងកំឡុងពេលមានជំងឺរាតត្បាតកូវីដ-១៩។

CGCC ជាសាជីវកម្មធានាឥណទានដំបូងគេនៅកម្ពុជា ដែលត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ជាសហគ្រាសគ្រប់គ្រងដោយរដ្ឋក្រោមការណែនាំបច្ចេកទេស និងហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បេសកកម្មចម្បងរបស់ CGCC គឺដើម្បីផ្តល់ការធានាឥណទានដល់ស្ថាប័នហិរញ្ញវត្ថុដែលចូលរួម (PFIs) ដើម្បីជួយគាំទ្រផ្នែកហិរញ្ញវត្ថុដល់អាជីវកម្ម ដែលរំពឹងថានឹងអាចមានលទ្ធភាពទទួលបានជោគជ័យ តែខ្វះខាតទ្រព្យបញ្ចាំនៅពេលដាក់ពាក្យស្នើសុំប្រាក់កម្ចី។

ការធ្វើអាជីវកម្មដំបូងរបស់ BRGS នឹងរួមចំណែកដល់ការបង្កើនប្រាក់កម្ចីថ្មីចំនួន ២០០លានដុល្លារ ក្នុងវិស័យធនាគារសម្រាប់ម្ចាស់អាជីវកម្ម ដើម្បីខ្ចីប្រាក់ពី PFIs របស់ CGCC ដូចជា ACLEDA Bank, Asia Pacific Development Bank, AMK MFI, Cambodia Post

Bank, Canadia Bank, Phillip Bank and Prince Bank។ គម្រោងនេះ ក៏នឹងមានផងដែរនៅតាមធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្សេងទៀតដែលកំពុងដំណើរ-ការក្លាយជា PFIs របស់CGCC។ ការធានារបស់ CGCC នឹងដើរតួជាទ្រព្យបញ្ចាំ/វត្ថុដាក់ធានាសម្រាប់៧០%-៨០% នៃចំនួនប្រាក់កម្ចី ពី PFIs ដែលរួមចំណែកដល់ការកាត់បន្ថយការដាក់ទ្រព្យបញ្ចាំដែលត្រូវការពីអ្នកខ្ចី។ ឯកឧត្តម **រស់ សីលាវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាលរបស់ CGCC បានលើកឡើងថា ការបើកដំណើរការគម្រោង BRGS ដោយ CGCC គឺមានលក្ខណៈទាន់ពេលវេលា ដើម្បីគាំទ្រដល់អាជីវកម្មទាំងឡាយណា ដែលមានគម្រោងខ្ចីប្រាក់ពី PFIs ក្នុងអំឡុងពេលជំងឺរាតត្បាតនេះ។ ការអនុវត្តបែបនេះ គឺដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីរក្សាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន និងស្របតាមគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មឆ្នាំ២០១៥-២០២៥។ ឯកឧត្តមក៏បានអំពាវនាវឱ្យធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គាំទ្រដល់ CGCC ដោយចូលរួមជាមួយ PFIs របស់ខ្លួន និងដើម្បីធានានូវអភិបាលកិច្ចផលទានល្អ៕ *ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ Khmer Times ចេញផ្សាយថ្ងៃទី២៩ ខែមីនាឆ្នាំ២០២១*

## តារាងប្រចាំសប្តាហ៍៖ ការប្រៀបធៀបតម្លៃផលិតផលនាំចេញប្រចាំខែកុម្ភៈ ឆ្នាំ២០២១ កំណើន ២៤% ធៀបនឹងខែមុន

តារាងខាងក្រោមនេះ បង្ហាញពីការប្រៀបធៀបការនាំចេញផលិតផលគ្រប់ប្រភេទក្នុងខែកុម្ភៈ ឆ្នាំ២០២១ ដែលមានកំណើន ២៤% បើធៀបនឹងខែមករា ឆ្នាំនេះ ដែលមានជាអាទិ៍៖ សំលៀកបំពាក់ វាយនភ័ណ្ឌ អង្ករ ស្បែកជើង កង់ កាបូបធ្វើដំណើរ និងផលិតផលផ្សេងៗ នេះបើយោងតាមព្រឹត្តិបត្រពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ដែលបានចេញផ្សាយនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១។

ការនាំចេញផលិតផលនៅខែកុម្ភៈ ឆ្នាំ២០២១នេះ មានកំណើនស្ទើរនៅលើគ្រប់មុខទំនិញទាំងអស់ ដែលរួមមាន៖ សំលៀកបំពាក់មានការកើន ១៤% ស្បែកជើងកើន៣% វាយនភ័ណ្ឌកើន ៣៤% អង្ករកើន ៥៧% និងផលិតផលផ្សេងៗវិញកើន ៦០% បើប្រៀបធៀបទៅនឹងខែមករា ឆ្នាំនេះ។ ដោយឡែក ការនាំចេញកាបូបធ្វើដំណើរថយចុះ ៤% និងកង់គ្មានសកម្មភាព បើធៀបនឹងរយៈពេលដូចគ្នា។

ទំនិញទាំងអស់ខាងលើនេះ ត្រូវបាននាំចេញទៅទីផ្សារពិភពលោកដែលរួមមាន៖ សហរដ្ឋអាមេរិកមានការកើនឡើង១៦% ជប៉ុន និងកូរ៉េខាងត្បូងកើនប្រមាណ១៥០% ដូចគ្នា អាស៊ានកើន៨៩% ចិនកើន១០៩% និងប្រទេសដទៃទៀត កើន១៧០% បើបៀបធៀបទៅនឹងខែមករា ឆ្នាំនេះ។ ចំណែកឯ កាណាដា និងសហគមអឺរ៉ុប គឺថយចុះ ២៧% និង ៤៦% រៀងគ្នា បើធៀបទៅនឹងកំឡុងពេលដូចគ្នា។ សរុបជារួម ការនាំចេញផលិតផលគ្រប់ប្រភេទទៅកាន់ទីផ្សារពិភពលោកនៅក្នុងខែកុម្ភៈ ឆ្នាំ

២០២១នេះ មានការកើនប្រមាណជា២៤% បើធៀបទៅនឹងខែមករា ឆ្នាំនេះ។

**បញ្ជាក់៖ ទិន្នន័យនេះមិនរាប់បញ្ចូលតំបន់សេដ្ឋកិច្ចពិសេសទេ។** *ដោយ ឈន ហាំ*

| ល.រ | ប្រភេទផលិតផល | ខែមករា ឆ្នាំ ២០២១ | ខែកុម្ភៈ ឆ្នាំ២០២១ | ភាគរយ (%) |
|---|---|---|---|---|
| | សរុបរួម | 910,480,260.44 | 1,132,880,174.72 | **24.43%** |
| 1 | សំលៀកបំពាក់ | 473,546,112.22 | 540,389,522.43 | 14.12% |
| 2 | ស្បែកជើង | 92,357,933.97 | 94,833,921.48 | 2.68% |
| ៣ | វាយនភ័ណ្ឌ | 8,374,579.17 | 11,258,785.68 | 34.44% |
| 4 | អង្ករ | 30,757,914.76 | 48,248,922.88 | 56.87% |
| 5 | ការបូបធ្វើដំណើរ | 80,104,242.85 | 77,302,141.07 | -3.50% |
| 6 | កង់ | 00.0 | 00.0 | 00.0% |
| 7 | ផលិតផលផ្សេងៗ | 225,339,477.47 | 360,846,881.18 | 60.13% |

| ល.រ | ទីផ្សារគោលដៅ | ខែមករា ឆ្នាំ២០២១ | ខែកុម្ភៈ ឆ្នាំ២០២១ | ភាគរយ (%) |
|---|---|---|---|---|
| | សរុបរួម | 910,480,260.44 | 1,132,880,174.72 | **24.43%** |
| 1 | សហរដ្ឋអាមេរិក | 277,229,982.37 | 321,577,030.72 | 16.00% |
| 2 | កាណាដា | 74,153,393.30 | 69,111,889.03 | -6.80% |
| ៣ | ជប៉ុន | 25,805,241.01 | 64,385,851.28 | 149.51% |
| 4 | សហគមអ៊ឺរ៉ុប | 279,104,030.59 | 151,792,963.76 | -45.61% |
| 5 | អាស៊ាន | 166,503,339.58 | 314,633,618.22 | 88.97% |
| 6 | ចិន | 38,882,402.80 | 81,372,729.22 | 109.28% |
| 7 | កូរ៉េខាងត្បូង | 6,466,069.00 | 16,138,175.27 | 149.58% |
| 8 | ប្រទេសដ៏ទៃទៀត | 42,335,801.79 | 113,867,917.22 | 168.96% |

*ប្រភព៖ ក្រសួងពាណិជ្ជកម្មកម្ពុជា ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### អត្រានៃការលក់រាយរបស់ប្រទេសជប៉ុនបានធ្លាក់ចុះក្នុងរយៈពេលបីខែជាប់គ្នា គិតត្រឹមខែកុម្ភៈ




*ប្រភព៖ Reuters ២០២១, រូបថត៖ Kim Kyung-Hoon*

គិតត្រឹមខែកុម្ភៈ ឆ្នាំ២០២១ ទិន្នន័យការលក់រាយរបស់ប្រទេសជប៉ុនបានធ្លាក់ចុះរយៈពេលបីខែជាប់គ្នា គិតចាប់ពីខែធ្នូ ឆ្នាំ២០២០ ដែលការធ្លាក់ចុះនេះបណ្តាលមកពីគ្រួសារជាច្រើនបានកាត់បន្ថយការចំណាយ ស្របពេលដែលកំពុងទទួលរងផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩។

យោងតាមការវិភាគរបស់អ្នកសេដ្ឋកិច្ចបានព្យាករណ៍ថា សេដ្ឋកិច្ចរបស់ប្រទេសជប៉ុន នឹងធ្លាក់ចុះយ៉ាងខ្លាំងក្នុងត្រីមាសទី១ ដោយសារតែការថមថយនូវចំណាយរបស់អតិថិជន និងការនាំចេញ ដែលបង្កជាបញ្ហាប្រឈមសម្រាប់អ្នកធ្វើគោលនយោបាយ ដែលបានដាក់ចេញនូវកម្មវិធីជួយឧបត្ថម្ភសាច់ប្រាក់ដ៏សម្បើមរួចមកហើយ។

ទន្ទឹមនឹងនេះ ទិន្នន័យរបស់រាជរដ្ឋាភិបាលបានបង្ហាញកាលពីពេលថ្មីៗនេះផងដែរថា ការលក់រាយបានធ្លាក់ចុះ១,៥% ក្នុងខែកុម្ភៈ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ

២០២០ ដែលការធ្លាក់ចុះនេះ គឺទាបជាងការព្យាករណ៍នៅលើទីផ្សារ ជាមធ្យមមានការធ្លាក់ចុះ២,៨%។ គួរបញ្ជាក់ផងដែរ នៅក្នុងខែធ្នូ ការលក់រាយធ្លាក់ចុះ ០,២% នឹងបានបន្តធ្លាក់ចុះ ២,៤% នៅក្នុងខែមករា។

លោក Atsushi Takeda ប្រធានសេដ្ឋកិច្ចវិទូនៅវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ច Itochu បានមានប្រសាសន៍ថា "ជំងឺកូវីដ-១៩ មិនទាន់ថមថយទេ ដែលជាបញ្ហាចម្បងត្រូវព្រួយបារម្ភអំពីការពន្យាពេលនៃការងើបឡើងវិញនៃសេដ្ឋកិច្ច"។

ទិន្នន័យការធ្លាក់ចុះនៃការលក់រាយគឺបណ្ដាលមកពីការធ្លាក់ចុះនៃការចំណាយលើទំនិញប្រើប្រាស់មួយចំនួនដូចជា៖ សម្លៀកបំពាក់ គ្រឿងសង្ហារឹម និងទំនិញប្រើប្រាស់ទូទៅ ព្រោះមនុស្សមិនចេញដើរក្រៅច្រើនដូចមុនដែលជាហេតុនាំឱ្យការលក់ធ្លាក់ចុះ។ នៅក្នុងខែមីនា ការលក់រាយបានកើនឡើង ៣,១% ធៀបនឹងខែមុន ដោយមានកែតម្រូវតាមរដូវកាល។

ទិន្នន័យដាច់ដោយឡែករបស់ក្រសួងការងារបានបង្ហាញថា អត្រាគ្មានការងារធ្វើដែលត្រូវបានកែតម្រូវតាមរដូវកាលនៅទូទាំងប្រទេស មានស្ថិរភាពត្រឹម ២,៩% ទាបជាងការព្យាករណ៍ ជាមធ្យម ៣%។ នៅក្នុងខែកុម្ភៈ ការងារទំនេរមានចំនួនប្រមាណ ១,០៩ កន្លែង ក្នុងចំណោមបេក្ខជនដាក់ពាក្យធ្វើការម្នាក់ ដែលធ្លាក់ចុះពី ១,១០កន្លែង ក្នុងបេក្ខជនដាក់ពាក្យធ្វើការម្នាក់ ក្នុងខែមករា។

ប្រទេសជប៉ុន ដែលជាប្រទេសសេដ្ឋកិច្ចធំបំផុតទី៣របស់ពិភពលោក ត្រូវបានព្យាករណ៍ថានឹងមានកំណើនធ្លាក់ចុះ ៦% នៅក្នុងត្រីមាស ដែលនេះជាការធ្លាក់ចុះលើកទី១ នៃរយៈពេល ៣ ត្រីមាស ក្នុងឆ្នាំ ដោយសារការចំណាយរបស់អ្នកប្រើប្រាស់ ការចំណាយក្នុងគ្រួសារ និងការនាំចេញចុះខ្សោយ ដែលធ្វើឱ្យមានការរំពឹងទុកនៃការងើបឡើងវិញនៃសេដ្ឋកិច្ចយឺតជាងការគិត៕

*ដោយ សេន ចន្ទី*

*ប្រភព៖ Reuters.com,ចេញផ្សាយថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១*

## តម្រូវការទីផ្សារការងារដែលមានភាពពេញនិយមនៅប្រទេសថៃកាលពីខែមុន




*ប្រភព៖ Bangkokpost ២០២១, Bangkok Post Graphics*

យោងតាមគេហទំព័រស្វែងរកការងាររបស់ប្រទេសថៃ (JobsDB) បានបង្ហាញថា កម្លាំងពលកម្មរបស់ប្រទេសថៃកំពុងមានការងើបឡើងវិញបន្ទាប់ពីការធ្លាក់ចុះកាលពីឆ្នាំមុន ដែលមានប្រជាជនចំនួន ៣លាននាក់ បានបាត់បង់ការងារ ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩។

ខណៈពេលដែលប្រទេសថៃត្រូវការទាក់ទាញជនបរទេសដែលមានជំនាញខ្ពស់មកធ្វើការនៅក្នុងប្រទេស ដូចនេះប្រជាជនថៃ គឺចាំបាច់ត្រូវមានការកែលម្អនូវជំនាញរបស់ខ្លួន ដើម្បីស្របតាមទស្សនវិស័យការងារ។

លោក Pornladda Dathratwibul អ្នកគ្រប់គ្រងនៅ JobsDB Thailand បានមានប្រសាសន៍ថា តម្រូវការនៃការងាររបស់ប្រទេសថៃបានងើបឡើងវិញកាលពីខែកុម្ភៈ ដោយផ្អែកលើវេទិកាស្វែងរកការងារ និងបណ្តាញអ៊ីនធឺណេតផ្សេងទៀត គឺមានអត្រា ២៤,៧% ធៀបនឹងទិន្នន័យឆ្នាំមុន។

ការប្រកាសការងារតាមអ៊ីនធឺណេត បានកើននៅក្នុងខែមេសា នៅពេលដែលការចុះបញ្ជីបានធ្លាក់ចុះ ៣៥,៦% ចាប់ពីខែមករា ឆ្នាំ២០២០ ។ នៅខែធ្នូកំឡុងពេលផ្ទុះជំងឺកូវីដ-១៩ ជាលើកទី២ ការប្រកាសការងារតាមបណ្តាញសង្គមបានធ្លាក់ចុះ៤៥,៥%ពីខែមករាឆ្នាំ ២០២០ ឬ ៣៧,៩% ពីខែសីហាឆ្នាំ២០២០។ ក្នុងនោះដែរ អ្នកគ្រប់គ្រង JobsDB បានរំពឹងថា ភាពមានការងារធ្វើរបស់ប្រទេសថៃនឹងកើនឡើងជិត៥% ជាប្រចាំនៅក្នុងឆ្នាំ២០២១។

ការលក់សេវាកម្មអតិថិជន និងការអភិវឌ្ឍអាជីវកម្ម គឺជាប្រភេទការងារ ដែលមានសមាមាត្រការងារខ្ពស់បំផុតដែលត្រូវបានដាក់នៅលើ JobsDB នៅក្នុងត្រីមាសដំបូងនៃឆ្នាំនេះ បន្ទាប់មកគឺបច្ចេកវិទ្យា និងវិស្វកម្ម។ បើប្រៀបធៀបត្រីមាសទី១ ឆ្នាំនេះជាមួយឆ្នាំមុន ការប្រកាសការងារសម្រាប់ទីផ្សារ និងទំនាក់ទំនងសាធារណៈ ឃើញថា មានកំណើនខ្ពស់បំផុត គឺ ២៩,៧% បន្ទាប់មកការដឹកជញ្ជូន និងភស្តុភារ ២៤,៧% និងការផលិតមាន ២០,៨%, ការងារព័ត៌មានវិទ្យាមានកំណើន ១០%។

ប្រាក់ខែនៅកម្រិតបុគ្គលិកព័ត៌មានវិទ្យាទទួលបានប្រាក់ឈ្នួលខ្ពស់បំផុតពី ២៣ 000 ទៅ ៤១ 000 បាតក្នុងមួយខែ បន្ទាប់មកអ្នកដែលមានជំនាញជាក់លាក់ដូចជាអ្នកបកប្រែភាសា អ្នកវិភាគអាជីវកម្ម និងមន្ត្រីច្បាប់ទទួលបានប្រាក់ឈ្នួល ២២ 000 ទៅ ៣៩ ០០០ បាត។ ចំណែកអ្នកដែលនៅក្នុងវិស័យទូរគមនាគមន៍អាចរំពឹងថានឹងទទួលបានប្រាក់ខែ ២២000 ទៅ ៣៨ 000បាត។

ប្រទេសថៃបានជាប់ចំណាត់ថ្នាក់ទី ៣៥ នៅលើពិភពលោក ដែលជាគោលដៅការងាររបស់ជនបរទេស កាលពីឆ្នាំមុន គឺកើនឡើងពីលេខ ៣៩ ក្នុងឆ្នាំ២០១៨ ខណៈដែលប្រទេសសិង្ហបុរីឈរនៅលំដាប់លើគេ។

នាពេលអនាគត ការងារដែលអាចរងផលប៉ះពាល់បំផុតពីបច្ចេកវិទ្យា គឺអ្នកដែលគ្មានជំនាញជាក់លាក់ដោយផ្តល់ប្រាក់ខែតិចជាង ៣ ម៉ឺនបាតក្នុងមួយខែ ក៏ដូចជាអ្នកម៉ៅការ ឬកម្មករបណ្តោះអាសន្នដោយចំណាយតិចជាង ១៦ ០០០ បាត៕

*ដោយ សេន ចន្ទី*

*ប្រភព៖ bangkokpost, ចេញផ្សាយថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១*

## សេដ្ឋកិច្ចសកល

### តម្លៃប្រេងកើនឡើង ដោយសារតែពាណិជ្ជកររំពឹងថា អង្គការ OPEC+ នឹងរក្សាការកាត់បន្ថយការផលិតប្រេង



*ប្រភព៖ Reuters ២០២១*

តម្លៃប្រេងឆៅ បានកើនឡើងខ្ពស់នៅថ្ងៃចន្ទ សប្តាហ៍នេះ បន្ទាប់ពីសារព័ត៌មាន Reuters បានរាយការណ៍ថា ប្រទេសរុស្ស៊ី នឹងគាំទ្រដល់ការរក្សាស្ថិរភាពទិន្នផលប្រេង ដោយអង្គការនៃប្រទេសនាំចេញប្រេង (OPEC+) មុនពេលកិច្ចប្រជុំនាពេលខាងមុខ ជាមួយប្រទេសផលិតប្រេង នៅចុងសប្តាហ៍នេះ។តម្លៃប្រេងបានធ្លាក់ចុះនៅកំឡុងពេលមុននេះ ដោយសារតែព័ត៌មានជុំវិញរឿងនាវាដឹកទំនិញយក្ស Ever Given ដែលបានជាប់គាំង និងបានរាំងស្ទះចរាចរណ៍ដល់នាវាដឹកជញ្ជូនទំនិញជាច្រើនផ្សេងទៀតនៅតាមព្រែកជីក Suez អស់រយៈពេលជិតមួយសប្តាហ៍ តែឥឡូវនេះអាចបំលាស់ទីឡើងវិញបានហើយ។

ជាក់ស្តែង តម្លៃប្រេងឆៅ Brent របស់អង់គ្លេស បានកើនឡើង២៦សេនដល់ ៦៤,៨៣ដុល្លារអាមេរិកក្នុងមួយបារ៉ែល នៅថ្ងៃចន្ទ ទី២៩ មីនា គិតត្រឹមម៉ោង១៧៖០៨នាទីល្ងាច ម៉ោងសកល (GMT) ខណៈដែលតម្លៃប្រេងឆៅរបស់សហរដ្ឋអាមេរិក West Texas Intermediate (WTI) បានកើនឡើង ៤៧សេន ដល់ ៦១,៤៤ដុល្លារអាមេរិកក្នុងមួយបារ៉ែល។

ប្រទេសរុស្ស៊ី នឹងគាំទ្រយ៉ាងពេញទំហឹងដល់ការរក្សាស្ថិរភាពទិន្នផលប្រេងដោយអង្គការ OPEC និងសម្ព័ន្ធមិត្តរបស់ពួកគេ រាប់បញ្ចូលទាំងប្រទេសរុស្ស៊ីផងដែរ (OPEC+) នៅក្នុងខែឧសភា ខណៈដែលប្រទេសរុស្ស៊ី នឹងបង្កើនការផលិតប្រេងបន្តិចសម្រាប់ប្រទេសខ្លួន ដើម្បីឆ្លើយតបនឹងការកើនឡើងនូវតម្រូវការតាមរដូវកាល នេះបើយោងតាមប្រភពព័ត៌មានដែលយល់ច្បាស់ពីការអនុវត្តកិច្ចការនេះរបស់ប្រទេសរុស្ស៊ី។

ជាមួយគ្នានេះដែរ យោងតាមប្រភពពីឧស្សាហកម្មផលិតប្រេងចំនួនពីរដែលធ្លាប់បានដឹងពីទិន្នន័យរបស់រុស្ស៊ី បានប្រាប់សារព័ត៌មាន Reuters ថា ទិន្នផលប្រេង និងឧស្ម័នរបស់រុស្ស៊ី បានកើនឡើងដល់ ១០,២២លានបារ៉ែល ក្នុងមួយថ្ងៃ ចាប់ពីថ្ងៃទី០១ ដល់ ២៨ ខែមីនា ពោលគឺកើនឡើងពី ១០,១លានបារ៉ែល ក្នុងមួយថ្ងៃ នៅក្នុងខែកុម្ភៈ ឆ្នាំ២០២១ ដែលទិន្នផលនេះ គឺវាស្របទៅតាមផែនការរបស់ទីក្រុងម៉ូស្គូ៕ *ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ គេហទំព័រសារព័ត៌មាន reuters ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ ២០២១*

## ជាងមួយភាគប្រាំនៃក្រុមហ៊ុននាំចេញតូចៗ របស់ចក្រភពអង់គ្លេស បញ្ឈប់ការលក់ជាបណ្ដោះអាសន្នទៅកាន់សហភាពអឺរ៉ុប




*ប្រភព៖ Reuters ២០២១, រូបភាព៖ Reuters/John Sibley*

យោងតាមការស្ទង់មតិរបស់សហព័ន្ធជាតិធុរកិច្ចខ្នាតតូច (FSB) ដែលទើបតែចេញផ្សាយថ្មីៗនេះ បានបង្ហាញថា ជាងមួយភាគប្រាំនៃក្រុមហ៊ុននាំចេញតូចៗ របស់ចក្រភពអង់គ្លេស បានបញ្ឈប់ការលក់ជាបណ្ដោះអាសន្នទៅកាន់សហភាពអឺរ៉ុប ខណៈដែលចំនួន៤% បានបញ្ឈប់ជាអចិន្ត្រៃយ៍។

បញ្ហាទាំងនេះ បានកើតឡើងដោយសារការអនុវត្តតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មនៃការចាកចេញរបស់អង់គ្លេស (Brexit) រវាងទីក្រុងឡុងដ៍ និងទីក្រុងប្រ៊ុចសែល ដែលកិច្ចព្រមព្រៀងពាណិជ្ជកម្មនេះ បានចូលជាធរមានកាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ និងបានបណ្ដាលឱ្យមានភាពអាក់អួល និងពន្យារពេលដល់ក្រុមហ៊ុនមួយចំនួនឱ្យមានដំណោះស្រាយជាមួយនឹងការិយាធិបតេយ្យ និងបទប្បញ្ញត្តិថ្មី។

បន្ថែមពីនេះ ក្រុមហ៊ុនដែលធ្វើជំនួញអន្តរជាតិ កំពុងជួបនូវផលវិបាកតាមរយៈការទាមទារនូវឯកសារ ដែលមិនសមហេតុផល និងមិនច្បាស់លាស់ នេះបើយោងតាមប្រសាសន៍របស់លោក Mike Cherry ប្រធានសហព័ន្ធជាតិធុរកិច្ចខ្នាតតូច។

ជាមួយគ្នានេះ យោងតាមការិយាល័យជាតិស្ថិតិបានឱ្យដឹងក្នុងខែមីនាថា ការនាំចេញទំនិញរបស់ចក្រភពអង់គ្លេសទៅកាន់សហភាពអឺរ៉ុប លើកលែងមាសមិនមែនជារូបិយវត្ថុ (non-monetary gold) និងលោហៈធាតុមានតម្លៃដទៃទៀត បានធ្លាក់ចុះ ៤០,៧% ក្នុងខែមករា ធៀបនឹងខែធ្នូ ឆ្នាំ២០២០ ខណៈដែលការនាំចូលធ្លាក់ចុះ ២៨,៨%។

ជាការឆ្លើយតបទៅនឹងតួលេខទាំងនេះ លោក David Frost អតីតប្រធានផ្នែកចរចារ Brexit របស់លោកនាយករដ្ឋមន្ត្រី Boris Johnson បាននិយាយថា «កត្តាជះឥទ្ធិពលរួមគ្នាពីការចាកចេញនេះ វាជារឿងមួយដែលជៀសមិនរួច ដែលធ្វើឱ្យយើងនឹងឃើញតួលេខមិនប្រក្រតីមួយចំនួន»៕

*ដោយ ស៊ិន សុភារ៉*

*ប្រភព៖ គេហទំព័រសារព័ត៌មាន Reuters ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្ដាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្ដាហ៍ខាងមុខនេះ រួមមាន៖ ទុនបម្រុងអន្តរជាតិរបស់ប្រទេសកូរ៉េខាងត្បូង អត្រាអតិផរណា

និងតុល្យភាពសាច់ប្រាក់ក្នុងរតនាគារនៅប្រទេសទួរគី ទុនបម្រុងអន្តរជាតិរបស់ប្រទេសម៉ិកស៊ិក ប្រាក់ចំណូលជាមធ្យមនៅប្រទេសជប៉ុន ការបម្រែបម្រួលភាគហ៊ុនប្រេងឆៅAPI ការបម្រែបម្រួលឥណទានប្រើប្រាស់ និងកាលក់ទំនិញដុំនៅសហរដ្ឋអាមេរិក ការបម្រែបម្រួលការងារក្រៅម៉ោងនៅប្រទេសកាណាដា និងតុល្យភាពពាណិជ្ជកម្មរបស់ប្រទេសបារាំង៕

ខាងក្រោម គឺជាប្រតិទិនដែលនាយកដ្ឋានស្រាវជ្រាវថវិកានឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

ថ្ងៃចន្ទ ទី០៥ ខែមេសា ឆ្នាំ២០២១

- ទុនបម្រុងអន្តរជាតិរបស់ប្រទេសកូរ៉េខាងត្បូង សម្រាប់ខែមីនា
- អត្រាអតិផរណានៅប្រទេសទួរគី ធៀបនឹងឆ្នាំមុន សម្រាប់ខែមីនា

ថ្ងៃអង្គារ ទី០៦ ខែមេសា ឆ្នាំ២០២១

- ទុនបម្រុងអន្តរជាតិរបស់ប្រទេសម៉ិកស៊ិក សម្រាប់ខែកុម្ភៈ
- ប្រាក់ចំណូលជាមធ្យមនៅប្រទេសជប៉ុន ធៀបនឹងឆ្នាំមុន សម្រាប់ខែកុម្ភៈ

ថ្ងៃពុធ ទី០៧ ខែមេសា ឆ្នាំ២០២១

- ការបម្រែបម្រួលភាគហ៊ុនប្រេងឆៅ API នៅសហរដ្ឋអាមេរិក សម្រាប់ថ្ងៃទី០២ ខែមេសា
- តុល្យភាពសាច់ប្រាក់ក្នុងរតនាគារ នៅប្រទេសទួរគី សម្រាប់ខែមេសា

ថ្ងៃព្រហស្បតិ៍ ទី០៨ ខែមេសា ឆ្នាំ២០២១

- ការបម្រែបម្រួលឥណទានប្រើប្រាស់នៅសហរដ្ឋអាមេរិក សម្រាប់ខែកុម្ភៈ
- តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសបារាំង សម្រាប់ខែកុម្ភៈ

ថ្ងៃសុក្រ ទី០៩ ខែមេសា ឆ្នាំ២០២១

- ការបម្រែបម្រួលការងារក្រៅម៉ោងនៅប្រទេសកាណាដា សម្រាប់ខែមីនា
- កាលក់ទំនិញដុំនៅសហរដ្ឋអាមេរិក ធៀបនឹងខែមុន សម្រាប់ខែកុម្ភៈ